ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

ក្រសួងសុខាភិបាល

# បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រី និងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ

ឆ្នាំ ២០១៦

រៀបចំឡើង ដោយមានការគាំទ្រពី៖

Australian Aid

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ:
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

# មាតិកា


**អារម្ភកថា** ........ **៣**

**សេចក្តីថ្លែងអំណរគុណ** ........ **៥**

**ពាក្យកាត់** ........ **៨**

**និយមន័យពាក្យសំខាន់ៗ** ........ **៩**

**១. សេចក្តីផ្តើម** ........ **១១**

១.១ គោលបំណង ........ ១២

១.២ ក្របខ័ណ្ឌច្បាប់ស្តីពីអំពើហិង្សាលើស្ត្រីក្នុងប្រទេសកម្ពុជា ........ ១៣

១.៣ តើអ្នកណាដែលគួរអនុវត្តបទដ្ឋានអប្បបរមាទាំងនេះ ? ........ ១៤

១.៤ ដែនកំណត់ ........ ១៤

**២. គោលការណ៍ណែនាំ និងគុណតម្លៃ សម្រាប់ផ្តល់ការថែទាំ ដែលផ្តោតលើជនរងគ្រោះ** ........ **១៦**

**៣. បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីជាជនរងគ្រោះ ដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ** ........ **១៨**

បទដ្ឋានទី១៖ ការផ្តល់ប្រឹក្សាជាមូលដ្ឋាន-ការជំរុញឱ្យមានការចូលរួមពីស្ត្រី ដែលជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ ........ **១៨**

បទដ្ឋានទី២ ៖ ការផ្តល់ប្រឹក្សាជាមូលដ្ឋាន-ការរៀបចំផែនការសុវត្ថិភាព សម្រាប់ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ ........ ១៩

បទដ្ឋានទី៣ ៖ ការផ្ដល់ប្រឹក្សាជាមូលដ្ឋាន-ការផ្ដល់ព័ត៌មានអំពីសេវា និង ការឆ្លើយតបដល់ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សារួមទាំង ជនដែលងាយរងគ្រោះផង ..... ២១

បទដ្ឋានទី៤ ៖ ការផ្ដល់ប្រឹក្សាជាមូលដ្ឋាន-ការផ្ដល់ជម្រើសការធ្វើសេចក្ដី សម្រេចចិត្តនិងការកំណត់ដោយខ្លួនឯង ..... ២៣

បទដ្ឋានទី៥ ៖ ការផ្ដល់ប្រឹក្សាជាមូលដ្ឋាន-ភាពជាឯកជន និងការរក្សាការសម្ងាត់ ..... ២៤

បទដ្ឋានទី៦ ៖ ការអនុវត្តល្អរបស់អ្នកផ្ដល់សេវា-ការស្គាល់ខ្លួនឯងរបស់អ្នក ផ្ដល់សេវា ..... ២៥

បទដ្ឋានទី៧ ៖ ការអនុវត្តល្អរបស់អ្នកផ្ដល់សេវា-ក្រមសីលធម៌ ក្នុងការទំនាក់ទំនងរវាងអ្នកផ្ដល់សេវានិងជនរងគ្រោះ ..... ២៦

បទដ្ឋានទី៨ ៖ ការអនុវត្តល្អរបស់អ្នកផ្ដល់សេវា-ការបង្កើតបណ្ដាញ និង ការបញ្ជូនរវាងអ្នកផ្ដល់សេវា ..... ២៧

បទដ្ឋានទី៩ ៖ ការអនុវត្តល្អរបស់អ្នកផ្ដល់សេវា-ការថែទាំខ្លួនឯងរបស់អ្នក ផ្ដល់សេវា ..... ២៧

បទដ្ឋានទី១០ ៖ ការអនុវត្តល្អរបស់អ្នកផ្ដល់សេវា-ការចុះអភិបាលណែនាំ និងការគាំទ្រដោយអ្នកផ្ដល់ប្រឹក្សាជំនាញ ..... ២៨

បទដ្ឋានទី១១ ៖ ការអនុវត្តល្អរបស់អ្នកផ្ដល់សេវា-ការបណ្ដុះបណ្ដាល អ្នកផ្ដល់សេវាឱ្យយល់ដឹងពីអំពើហិង្សាដែលទាក់ទងនឹង យេនឌ័រ និងជំនាញផ្ដល់សេវាជាមូលដ្ឋាន ..... ២៩


ទំព័រ ៤

# អារម្ភកថា

បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រត្រូវបានរៀបចំឡើងដោយក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការគាំទ្រពីគម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រីដែលអនុវត្តរួមគ្នាដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (**GIZ**) និងក្រសួងកិច្ចការនារីដែលទទួលបានមូលនិធិពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហព័ន្ធអាល្លឺម៉ង់ (**BMZ**) និងក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (**DFAT**)។

បទដ្ឋានអប្បបរមាទាំងនេះ គឺស្របគ្នាជាមួយនឹងចំណុចដៅទី៤នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិពោលគឺ បង្កើនការអនុវត្តគោលនយោបាយប្រជាសាស្ត្រ និងសមធម៌យេនឌ័រ។ ការពង្រឹងសមធម៌យេនឌ័រដែលជាអាទិភាពមួយក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា គូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា ត្រូវលើកកម្ពស់ការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៤-២០១៨) (ដែលហៅកាត់ថា **NAPVAW**) ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រីស្របតាមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (**CEDAW**)។ បើតាមយុទ្ធសាស្ត្រទី២ ក្រោមលទ្ធផលរំពឹងទុកទី១០ នៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីស្តីពីកិច្ចការពារផ្លូវច្បាប់ និងសេវាកម្មពហុវិស័យ មានការរំពឹងទុកថាក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល នឹងរៀបចំបទដ្ឋានអប្បបរមាដើម្បីធ្វើឱ្យកាន់តែប្រសើរនូវជំនាញផ្តល់ប្រឹក្សាជាមូលដ្ឋានរបស់អ្នកផ្តល់សេវានានាដើម្បីឱ្យពួកគេអាចផ្តល់សេវាសមស្របកាន់តែមានគុណភាព និងប្រសិទ្ធភាពជាងមុន និងទាន់ពេលវេលាដល់ជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រទាំងអស់។

បទដ្ឋានអប្បបរមាទាំងនេះមានគោលបំណងផ្តល់ការណែនាំដល់អ្នកផ្តល់សេវាទាំងអស់ដើម្បីឱ្យពួកគេចេះប្រើប្រាស់អភិក្រម/វិធីសាស្ត្រសិទ្ធិមនុស្សផ្តល់សេវាដល់ជនរងគ្រោះ។ នេះមានន័យថាពួកគេត្រូវគោរពការសម្រេចចិត្តរបស់ជនរងគ្រោះនិងធានាយ៉ាងណាឱ្យជនរងគ្រោះទទួលបានព័ត៌មានគ្រប់គ្រាន់។ បទដ្ឋានអប្បបរមាទាំងនេះលើកទឹកចិត្តអ្នកផ្តល់សេវាទាំងនេះឱ្យបញ្ជូនជនរងគ្រោះទៅរកសេវាដែលចាំបាច់សម្រាប់ពួកគេនៅកន្លែងដែលមានសេវា។ ការផ្តល់ភាពអង់អាចដល់ជនរងគ្រោះនឹងនាំឱ្យមានផលជាវិជ្ជមាន លើការកសាងទំនុកចិត្តរបស់ពួកគេដើម្បីឱ្យជនរងគ្រោះអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបាន។

បទដ្ឋានអប្បបរមាទាំងនេះគ្រួសត្រាយផ្លូវឱ្យមានការផ្តល់ការឆ្លើយតបដ៏ទូលំទូលាយនិងគ្រប់ជ្រុងជ្រោយលើករណីអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ  ដោយធ្វើការពិចារណាពីសុវត្ថិភាពរបស់ស្ត្រី និងកូនៗរបស់ពួកគេ។ គួរមានការបណ្តុះបណ្តាលដល់អ្នកផ្តល់សេវាទាំងនេះអំពីរបៀបអនុវត្តបទដ្ឋានអប្បបរមាទាំងនេះ  ដើម្បីផ្តល់សេវាប្រកបដោយវិជ្ជាជីវៈដល់ជនរងគ្រោះប្រកបដោយការគោរព និងការយកចិត្តទុកដាក់។

ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាលមានជំនឿ និងសេចក្តីសង្ឃឹមថាបទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រី  និងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រនេះនឹងផ្តល់ការណែនាំងាយស្រួលសម្រាប់ឱ្យអ្នកផ្តល់សេវាអនុវត្តតាមក្នុងការបំពេញការងារប្រចាំថ្ងៃរបស់ខ្លួន។

ធ្វើនៅរាជធានីភ្នំពេញ

ថ្ងៃទី ខែ ឆ្នាំ២០១៦ | ថ្ងៃទី ខែ ឆ្នាំ២០១៦

រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | រដ្ឋមន្ត្រីក្រសួងសុខាភិបាល

អ៊ឹង កន្ថាផាវី | ម៉ម ប៊ុនហេង

# សេចក្ដីថ្លែងអំណរគុណ

ដំណើរការរៀបចំបទដ្ឋានអប្បបរមាសម្រាប់ការផ្ដល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រី និងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រនេះ ត្រូវបានផ្ដួចផ្ដើមឡើង ក្នុងឆ្នាំ២០១៣ ដោយមានការពិគ្រោះយោបល់ជាមួយនឹងអ្នកជំនាញជាតិ និងអន្តរជាតិ។ បទដ្ឋានអប្បបរមានេះរៀបរាប់ពីអ្វីដែលអ្នកផ្ដល់សេវាគួរធ្វើនៅក្នុងដំណើរការនៃការផ្ដល់ប្រឹក្សាជាមូលដ្ឋានដល់ជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ សំដៅធានាឱ្យមានការគោរពសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ និងផ្ដល់អំណាចឱ្យពួកគេធ្វើការសម្រេចចិត្តដោយខ្លួនឯង។

ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល បានសហការគ្នាក្នុងក្រុមការងារអន្តរក្រសួងដែលត្រូវបានបង្កើតឡើងដើម្បីរៀបចំបទដ្ឋានអប្បបរមានេះដោយមានការគាំទ្រពីគម្រោង **ATJW** ក្រោមការឧបត្ថម្ភមូលនិធិពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហព័ន្ធអាល្លឺម៉ង់ (BMZ) និងក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (**DFAT**) (ពីឆ្នាំ២០១៤ដល់២០១៦) និងទីភ្នាក់ងារអេស្ប៉ាញ សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ (**AECID**) (ពីឆ្នាំ២០១០ដល់២០១៣)។

ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល សូមថ្លែងអំណរគុណដល់សមាជិកទាំងអស់ក្រុមការងារអន្តរក្រសួង និងអ្នកជំនាញដែលបានចូលរួមក្នុងការពិគ្រោះយោបល់ក្នុងដំណើរការនេះ។ សមាជិកក្រុមការងារអន្តរក្រសួងនេះ រួមមាន លោកជំទាវ **ស៊ី ដេហ្វីន** រដ្ឋលេខាធិការក្រសួងកិច្ចការនារី លោកជំទាវ **តាន់ វួចឆេង** រដ្ឋលេខាធិការ ក្រសួងសុខាភិបាល លោកជំទាវ **ទេស ចន្ទ័សារឿន** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី ឯកឧត្តម **ឈុំ វណ្ណារិទ្ធ** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល លោកស្រី **សាខឿន សាវ៉ាតឌី** អគ្គនាយករងក្រសួងកិច្ចការនារី វេជ្ជ. **សួ សាឡន** អគ្គនាយករងបច្ចេកទេសក្រសួងសុខាភិបាល លោកស្រី វេជ្ជ. **ឆាយគីម សុទ្ធារី** ប្រធាននាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំយុវជន និងកីឡា លោកស្រី **កាន់ សុធារី** មន្ត្រីនាយកដ្ឋានសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា លោក **ឈិត សុផល** ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន វេជ្ជ. **មុនី សុត្ថារា** មន្ត្រីផ្នែកសុខភាពផ្លូវចិត្តនៃមន្ទីរពេទ្យព្រះកុសមៈក្រសួងសុខាភិបាល លោក **ជីន ចន** អនុប្រធាននាយកដ្ឋានកិច្ចការពារផ្លូវច្បាប់ក្រសួងកិច្ចការនារី លោកស្រី **ស ស៊ីណេត** អនុប្រធាននាយកដ្ឋានកិច្ចការពារផ្លូវច្បាប់ក្រសួងកិច្ចការនារី ឧត្តមសេនីយ៍ទោ **គឹម ភាព** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្រសួងមហាផ្ទៃ លោកស្រី **ជូ ផល្លីកា** អនុប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀនក្រសួងសុខាភិបាល

លោក **យឹម សុបុត្រា** ប្រធានផ្នែកសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀនមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតក្រសួងសុខាភិបាល លោកស្រីវេជ្ជបណ្ឌិត **សៅ ចំរើន** មន្ត្រីនាយកដ្ឋានសុខភាពផ្លូវចិត្ត និងការប្រើបំពានគ្រឿងញៀនក្រសួងសុខាភិបាល លោកស្រី **គង់ ដារារដ្ឋ** និងលោកស្រី **សួន រដ្ឋា** មន្ត្រីនាយកដ្ឋានពេទ្យការងារ លោកស្រី **សុខ ចាន់រស្មី** មន្ត្រីការិយាល័យច្បាប់ ក្រសួងកិច្ចការនារី លោក **ឈឹម សុធារ៉ា** នាយកប្រតិបត្តិ អង្គការ **TPO** លោកស្រី **Ellen Minotti** ទីប្រឹក្សានៃអង្គការសេវាសង្គមកម្ពុជា លោកស្រី **សុខ ផាណែត** ប្រធានគ្លីនិកសុខភាពផ្លូវចិត្តអង្គការ **TPO** លោក **អ៊ុក ប៊ុនធឿន** ប្រធានផ្នែកបណ្តុះបណ្តាលអង្គការសេវាសង្គមកម្ពុជាលោកស្រី **ម៉ាង ចិន្តា** អ្នកបណ្តុះបណ្តាល អង្គការសេវាសង្គមកម្ពុជា លោក **ផាន់ គឹមគ្រៀន** មន្ត្រីផ្នែកគ្រប់គ្រងកំហឹង មជ្ឈមណ្ឌលសង្គ្រោះស្ត្រីមានវិបត្តិកម្ពុជា (**CWCC**) លោក **អ៊ាន នីល** សាស្ត្រាចារ្យចិត្តវិទ្យាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ លោកស្រី **ជា សំណាង** សាស្ត្រាចារ្យចិត្តវិទ្យាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងលោក **ពេជ្រ បញ្ញា** អភិបាលកិច្ចគ្លីនិកអង្គការចិត្តសង្គមអន្តរវប្បធម៌ (**TPO**)។

លើសពីនេះយើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកស្រី **យូ សុភា** អតីតប្រធានមន្ទីរកិច្ចការនារីខេត្តសៀមរាប និងលោកស្រី **ស៊ុន ស៊ីផាន** ប្រធានមន្ទីរកិច្ចការនារីខេត្តកំពង់ធំ និងសហការី ដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងអ្នកផ្តល់សេវានានា និងជួយសម្របសម្រួលការបណ្តុះបណ្តាលសាកល្បងជាមួយនឹងអ្នកពាក់ព័ន្ធនៅថ្នាក់ស្រុក និងឃុំ ដើម្បីជានាឱ្យមានការផ្តល់សេវាប្រកបដោយគុណភាព និងប្រសិទ្ធភាពដល់ជនរងគ្រោះដោយអំពើហិង្សា។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកស្រី **ប៊ូ មករា** ទីប្រឹក្សាថ្នាក់ជាតិនៃគម្រោង **ATJW II** ដែលបានជួយសម្របសម្រួលដំណើរការបង្កើតបទដ្ឋានអប្បបរមានេះឡើង ក្រោមការណែនាំរបស់ លោកស្រី បណ្ឌិត **Dagmar Baer** អ្នកគ្រប់គ្រងកម្មវិធី **ATJW II** របស់ **GIZ**។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់លោកស្រី **Robin Mauney** ទីប្រឹក្សាគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី (**EVAW**) ដែលបានផ្តល់នូវធាតុចូលយ៉ាងច្រើនដើម្បីកែលំអ និងបញ្ចប់បទដ្ឋានអប្បបរមានេះ និងលោកស្រី **Cheryl Clay** អ្នកគ្រប់គ្រងកម្មវិធី **EVAW** ប្រចាំប្រទេសកម្ពុជារបស់ **DFAT** និងលោក **Rodrigo Montero Cano** ទីប្រឹក្សាអន្តរជាតិរបស់គម្រោង **ATJW II** នៃ **GIZ** ដែលបានផ្តល់ធាតុចូលបន្ថែមក៏ដូចជាជំបូន្មានបច្ចេកទេសក្នុងដំណើរការនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរដល់អ្នកដែលបានចូលរួមក្នុងកិច្ចប្រជុំសហគមន៍អ្នកអនុវត្តការងារ (**Community of Practice**) ក្នុងខេត្តសៀមរាប និងខេត្តកំពង់ធំដើម្បីពិនិត្យឡើងវិញ និងផ្តល់ព័ត៌មានត្រឡប់ដើម្បីឱ្យបទដ្ឋានអប្បបរមានេះកាន់តែមានលក្ខណៈល្អប្រសើរមួយកម្រិតទៀតដូចជាមន្ទីរសុខាភិបាល មន្ទីរពេទ្យខេត្ត គណៈឆ្មប មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ការិយាល័យប្រឆាំងការជួញដូរមនុស្សស្នងការនគរបាលខេត្ត អង្គការជំនួយផ្លូវច្បាប់កម្ពុជា អង្គការបន្ទាយស្រី អង្គការជួយសង្គ្រោះស្ត្រីមានវិបត្តិ អង្គការជនពិការ អង្គការ **Aple** អង្គការកល្យាណមិត្ត មជ្ឈមណ្ឌលធនធានស្ត្រី អង្គការជីវិតនៅកម្ពុជា និងមន្ទីរអប់រំ យុវជន និងកីឡានៃខេត្តទាំងពីរ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់ក្រុមការងារដែលបានផ្តួចផ្តើមរៀបចំសេចក្តីព្រាងបទដ្ឋានអប្បបរមានេះឡើងដូចជា **Summer Benton** មកពីអង្គការ **World Hope International** លោកស្រី **Meng Daly** ទីប្រឹក្សា លោកស្រី **Elizabeth Hoegger** ទីប្រឹក្សាខាងចិត្តវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ លោក **Seng Mang** បុគ្គលិកអង្គការ **Hagar** លោកស្រី **Grusche Michelsen** មកពី **Child Helpline Cambodia** លោកស្រី **Ellen Minotti** អង្គការសេវាសង្គមកម្ពុជាលោក **Tony Posnett** មកពីអង្គការ **Hagar** លោកគឹមរស្មីមកពីអង្គការ **AFESIP** កម្ពុជា និងបុគ្គលិកគម្រោង **ATJW** របស់ **GIZ** ដូចជាលោកស្រី **Linda Helfrich** ទីប្រឹក្សាអន្តរជាតិ លោកស្រី **Kristina Beck** ទីប្រឹក្សា និងលោកស្រី **គង់ សុភា**ទីប្រឹក្សាជាតិ។

ការរៀបចំ និងការបោះពុម្ពផ្សាយបទដ្ឋានអប្បបរមានេះអាចធ្វើទៅបានដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់ (**BMZ**) ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (**DFAT**) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិ (ពីឆ្នាំ២០១០ ដល់ ២០១៣)។

# ពាក្យកាត់

| | |
|---|---|
| **AECID** | ភ្នាក់ងារអេស្ប៉ាញសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ |
| **ATJW** | គម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រី (២០១០-២០១៣) |
| **ATJW II** | គម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រីទី២ (២០១៤-២០១៦) |
| **BMZ** | ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហព័ន្ធអាល្លឺម៉ង់ |
| **CCWC** | មជ្ឈមណ្ឌលជួយស្ត្រីកម្ពុជាមានវិបត្តិ |
| **CEDAW** | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| **COP** | សហគមន៍អ្នកអនុវត្តការងារ |
| **DFAT** | ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី |
| **EVAW** | គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី |
| **GBV** | អំពើហិង្សាដែលទាក់ទងនឹងយេនឌ័រឬអំពើហិង្សាផ្អែកលើយេនឌ័រ |
| **GIZ** | ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ |
| **LAC** | អង្គការជំនួយច្បាប់នៅកម្ពុជា |
| **MoH** | ក្រសួងសុខាភិបាល |
| **MoSVY** | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **MoWA** | ក្រសួងកិច្ចការនារី |
| **PDoWA** | មន្ទីរកិច្ចការនារី |
| **NAPVAW** | ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **RUPP** | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| **TPO** | អង្គការចិត្តសង្គមអន្តរវប្បធម៌ |
| **VAW** | អំពើហិង្សាលើស្ត្រី |

# និយមន័យពាក្យសំខាន់ៗ

**ការផ្តល់ប្រឹក្សាជាមូលដ្ឋាន** ៖ របៀបដែលអ្នកផ្តល់សេវាធ្វើការប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះ និងផ្តល់ការថែទាំដើម្បីបំពេញតម្រូវការផ្លូវចិត្ត និងតម្រូវការជាក់ស្តែងបន្ទាន់នានារបស់ពួកគេ។

**ការផ្តល់ប្រឹក្សា** ៖ ដំណើរការមួយដែលរៀបចំឡើងជាជំហានៗក្នុងគោលបំណងជួយមនុស្សទប់ទល់ ឬសម្របខ្លួនទៅនឹងស្ថានភាពដែលពួកគេកំពុងប្រឈម។ ការផ្តល់ប្រឹក្សារួមមានការជួយបុគ្គលណាម្នាក់ឱ្យយល់ពីអារម្មណ៍របស់ខ្លួនដើម្បីជួយពួកគេឱ្យជ្រើសរើសយកជម្រើសនិងធ្វើសេចក្តីសម្រេចចិត្តជាវិជ្ជមាន។

**ការបង្ខិតបង្ខំ** ៖ ការបង្ខំឬការប៉ុនប៉ងបង្ខំមនុស្សម្នាក់ទៀតឱ្យប្រឡូកក្នុងឥរិយាបថដែលគេមិនចង់ធ្វើដូចជាតាមរយៈការប្រើប្រាស់ការគំរាមកំហែងការនិយាយទទូចដដែលៗ ការបំផ្លើសការបោកបញ្ឆោតការរំពឹងទុកខាងវប្បធម៌ ឬ ការប្រើប្រាស់អំណាចសេដ្ឋកិច្ច។

**ការយល់ព្រម** ៖ ការធ្វើសេចក្តីសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវដោយសេរី និងដោយស្ម័គ្រចិត្តដើម្បីធ្វើអ្វីមួយ។ពុំចាត់ទុកជាការយល់ព្រមឡើយនៅពេលដែលការយល់ព្រមនេះទទួលបានតាមរយៈការប្រើប្រាស់ការគំរាមកំហែង ការបង្ខំក្នុងទម្រង់ផ្សេងៗ ការជំរិត ការកេងបន្លំការបោកបញ្ឆោត ឬការបំភ័ន្ត។

**អំពើហិង្សាក្នុងគ្រួសារ** ៖ អំពើហិង្សាក្នុងគ្រួសារដែលត្រូវបានកំណត់និយមន័យក្នុងច្បាប់របស់ប្រទេសកម្ពុជារួមមានអំពើហិង្សាលើប្តី ឬ ប្រពន្ធកូនក្នុងបន្ទុក ឬអ្នករស់នៅក្រោមដំបូលផ្ទះតែមួយ និងអ្នកដែលស្ថិតក្រោមបន្ទុករបស់គ្រួសារ។

**អ្នកមានកាតព្វកិច្ច** ៖ អ្នកមានកាតព្វកិច្ច គឺជាតួអង្គដែលមានកាតព្វកិច្ចឬការទទួលខុសត្រូវពិសេសក្នុងការគោរពលើកកម្ពស់ និងសម្រេចឱ្យបាននូវសិទ្ធិមនុស្ស និងមិនបំពានសិទ្ធិមនុស្ស។ ពាក្យនេះ គេច្រើននិយមប្រើសម្រាប់តួអង្គរដ្ឋប៉ុន្តែតួអង្គមិនមែនរដ្ឋក៏គេអាចទុកថាជាអ្នកមានកាតព្វកិច្ចផងដែរ។ បុគ្គល (ដូចជាមាតាបិតា) អង្គការនៅមូលដ្ឋាន ក្រុមហ៊ុនឯកជន ម្ចាស់ជំនួយ និងស្ថាប័នអន្តរជាតិក៏អាចជាអ្នកមានកាតព្វកិច្ចដែរ។

**អំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ៖** អំពើហិង្សាដែលទាក់ទងនឹងយេនឌ័រត្រូវបានកំណត់និយមន័យក្នុងឯកសារនេះថាជា "អំពើហិង្សាលើស្ត្រីដោយសារតែនាងជាស្ត្រី ឬអំពើហិង្សាដែលមានផលប៉ះពាល់លើសលប់លើស្ត្រី។ ពាក្យនេះគ្របលើទង្វើដែលនាំឱ្យមានគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ អារម្មណ៍ផ្លូវចិត្ត ឬ ផ្លូវភេទ ការគំរាមកំហែងប្រព្រឹត្តទង្វើទាំងនេះ ការបង្ខិតបង្ខំ និងការបំបិទសេរីភាពផ្សេងទៀត។"

**អំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល** សំដៅលើឥរិយាបថរបស់ដៃគូស្និទ្ធស្នាល ឬអតីតដៃគូស្និទ្ធស្នាលដែលបង្កឱ្យមានគ្រោះថ្នាក់ផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត ដូចជាការឈ្លានពានលើរាងកាយការបង្ខិតបង្ខំផ្លូវភេទ និងការរំលោភបំពានផ្លូវចិត្ត និងឥរិយាបថត្រួតត្រាជាដើម។

**អ្នកប្រព្រឹត្ត** ៖ ក្រុមមនុស្ស ឬស្ថាប័នដែលបង្កគាំទ្រ និងការពារការប្រព្រឹត្តអំពើហិង្សា ឬការរំលោភបំពានផ្សេងទៀតលើមនុស្សណាម្នាក់ ឬក្រុមណាមួយដោយផ្ទាល់ឬដោយប្រយោល។

**អ្នកផ្តល់សេវា** ៖ អង្គការបុគ្គលិកអ្នកស្ម័គ្រចិត្ត និងអ្នកមានកាតព្វកិច្ចទាំងអស់ដែលផ្តល់សេវា និងការគាំទ្រដល់ជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។

**អំពើហិង្សាផ្លូវភេទ** គឺជាទង្វើផ្លូវភេទ ការប៉ុនប៉ងធ្វើអំពើផ្លូវភេទ ការផ្តល់យោបល់ ឬសម្តីលែបខាយដែលគេមិនចង់បាន ឬទង្វើជួញដូរមនុស្ស ឬទង្វើផ្សេងទៀតដែលផ្តោតលើលក្ខណៈផ្លូវភេទរបស់មនុស្សម្នាក់ដោយប្រើប្រាស់ការបង្ខិតបង្ខំរបស់មនុស្សណាម្នាក់មិនថា មនុស្សម្នាក់នោះមានទំនាក់ទំនងបែបណាជាមួយជនរងគ្រោះនោះទេ ទោះជាក្នុងបរិបទបែបណាក៏ដោយ ដូចជាក្នុងផ្ទះ ឬកន្លែងការងារ និងកន្លែងផ្សេងទៀតជាដើម។

**ជនរងគ្រោះ** ៖ ជនដែលត្រូវបានគេរំលោភបំពានផ្លូវកាយ ផ្លូវភេទ និង/ឬផ្លូវចិត្ត និងដែលកំពុងទទួលបានសេវាពីអ្នកផ្តល់សេវា។ អ្នកផ្តល់សេវាមួយចំនួនហៅជនរងគ្រោះថាជាអតិថិជន អ្នកជំងឺ ជនរងគ្រោះដោយសារបទល្មើស ឬ ហៅតាមបែបផ្សេងទៀត។

**អំពើហិង្សាលើស្ត្រី** ៖ ទង្វើអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រដែលនាំឱ្យមាន ឬទំនងជាបង្កឱ្យមានគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តដល់ស្ត្រីរួមនឹងការគំរាមកំហែងប្រព្រឹត្តទង្វើទាំងនេះ ការបង្ខិតបង្ខំ ការបំបិទសេរីភាពតាមអំពើចិត្តមិនថាកើតមានឡើងនៅទីសាធារណៈ ឬជីវិតឯកជននោះទេ។

ពស៌ ៥

# ១. សេចក្តីផ្តើម

អំពើហិង្សាលើស្ត្រី គឺជាការរំលោភបំពានសិទ្ធិមនុស្សដែលមានផលប៉ះពាល់លើជីវិតរបស់ស្ត្រី។ យោងតាមលទ្ធផលនៃការស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោករកឃើញថា ស្ត្រី១នាក់ក្នុងចំណោមស្ត្រី៣នាក់ នៅជុំវិញពិភពលោក មានបទពិសោធន៍អំពីអំពើហិង្សាផ្លូវកាយ ឬ/នឹងអំពើហិង្សាផ្លូវភេទពីដៃគូរបស់គាត់ ឬអំពើហិង្សាផ្លូវភេទពីអ្នកមិនមែនជាដៃគូរបស់ខ្លួន។[១] អ្នកផ្តល់សេវាមានការទទួលខុសត្រូវឆ្លើយតបចំពោះជនរងគ្រោះដោយត្រូវធ្វើការពិចារណាលើទិដ្ឋភាពសង្គមនៃអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រក៏ដូចជាលើសិទ្ធិ និងតម្រូវការជាក់លាក់របស់ជនរងគ្រោះ។ ជាទូទៅ ជនរងគ្រោះនៃអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រមិនសូវទុកចិត្តអ្នកផ្តល់សេវាទេ ហើយជនរងគ្រោះអាចជួយបិទបាំងកំហុសរបស់ជនមុខសញ្ញាឱ្យមានកាន់តែតិចទៅៗ ហើយនឹងការពារជនមុខសញ្ញា។ កត្តាទាំងនេះនឹងបណ្តាលឱ្យមានផលប៉ះពាល់នូវការឆ្លើយតបរបស់អ្នកជាមួយនឹងជនរងគ្រោះ។ ចំនុចទាំងនេះ មានសារៈសំខាន់សម្រាប់ការបណ្តុះបណ្តាលនៅពេលអនាគត។ លើសពីនេះ អ្នកផ្តល់សេវាត្រូវធ្វើការងាររបស់ខ្លួនក្នុងក្របខ័ណ្ឌនៃការឆ្លើយតបពហុវិស័យ[២] ហើយដើម្បីធ្វើបែបនេះបានទាមទារឱ្យពួកគេដឹងពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាផ្សេងទៀត។

ការផ្តល់ប្រឹក្សាជាមូលដ្ឋាន គឺជាដំណើរការដែលមានលក្ខណៈអន្តរកម្មរវាងអ្នកផ្តល់សេវា និងស្ត្រីដែលក្នុងដំណើរការនេះមានការផ្លាស់ប្តូរព័ត៌មានរវាងគ្នាទៅវិញទៅមក និងមានការផ្តល់ការគាំទ្រ ដើម្បីឱ្យស្ត្រីអាចធ្វើការសម្រេចចិត្តរៀបចំផែនការ និងធ្វើសកម្មភាពទៅតាមការសម្រេចចិត្តរបស់ពួកគេដែលធ្វើឡើងផ្អែកទៅតាមព័ត៌មានត្រឹមត្រូវ។ បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ (ដែលហៅកាត់ថាបទដ្ឋានអប្បបរមា) នេះនឹងផ្តល់ការណែនាំអំពីរបៀបប្រតិបត្តិជាមួយជនរងគ្រោះដល់អ្នកផ្តល់សេវាដែលជាអ្នកនៅជួរមុខ ក្នុងការប្រាស្រ័យទាក់ទងជាមួយស្ត្រីដែលទទួលរងអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។

---

១ http://www.who.int/reproductivehealth/publications/violence/VAW_infographic.pdf?ua=1

២ ការឆ្លើយតបពហុវិស័យនេះអំពាវនាវឱ្យមានកិច្ចខិតខំប្រឹងប្រែងអន្តរស្ថាប័ន និងអន្តរទីភ្នាក់ងារមានលក្ខណៈក្តោបរួមដែលជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីបុគ្គលពាក់ព័ន្ធ កិច្ចសហប្រតិបត្តិការអន្តរជំនាញ និងអន្តរស្ថាប័ន និងការសហការ និងការសម្របសម្រួលរវាងវិស័យសំខាន់ៗជាអាទិ៍វិស័យសុខាភិបាលចិត្ត សង្គម ច្បាប់/យុត្តិធម៌ និងសន្តិសុខជាដើម។ ប្រភព៖ http://www.endvawnow.org/en/articles/1503-the-multi-sectoral-model.html

### អំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ

អំពើហិង្សាដែលទាក់ទងនឹងយេនឌ័រគឺជា "អំពើហិង្សាលើស្ត្រីដោយសារតែនាងជាស្ត្រី ឬដែលមានផលប៉ះពាល់លើសលប់លើស្ត្រី។ អំពើហិង្សា រួមមានទង្វើដែលបង្កឱ្យមានគ្រោះថ្នាក់

ឬការឈឺចាប់ផ្លូវកាយផ្លូវចិត្ត ឬផ្លូវភេទ ការគំរាមប្រព្រឹត្តទង្វើបែបនេះការបង្ខិតបង្ខំ និងការបំបិទសេរីភាពផ្សេងទៀត។

(ក) អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តដែលកើតឡើងក្នុងរង្វង់គ្រួសារដូចជាការវាយដំ ការរំលោភបំពានផ្លូវភេទលើកូនស្រីក្នុងគ្រួសារ អំពើហិង្សាពាក់ព័ន្ធនឹងបណ្ណាការ ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ការកាត់ច្រឹបប្រដាប់ភេទស្ត្រី និងការប្រព្រឹត្តបែបប្រពៃណីផ្សេងទៀត ដែលនាំឱ្យមានគ្រោះថ្នាក់ដល់ស្ត្រី អំពើហិង្សាដែលប្រព្រឹត្តដោយអ្នកមិនមែនជាសហព័ទ្ធ និងអំពើហិង្សាពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច។

(ខ) អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តដែលកើតឡើងក្នុងសហគមន៍ទូទៅដូចជាការរំលោភសេពសន្ថវៈ ការរំលោភបំពានផ្លូវភេទ ការបៀតបៀនផ្លូវភេទ និងការគំរាមកំហែងនៅកន្លែងការងារ តាមគ្រឹះស្ថានអប់រំ និងកន្លែងផ្សេងទៀត ការជួញដូរមនុស្ស និងការបង្ខំឱ្យធ្វើជាពេស្យាចារ។

(គ) អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តដែលប្រព្រឹត្តឬគាំទ្រដោយរដ្ឋមិនថាវាកើតឡើងនៅទីណានោះទេ។

*ប្រភព៖ អនុសាសន៍ទូទៅលេខ១៩ របស់គណៈកម្មាធិការ CEDAW, កម្មវិធីសកម្មភាពទីក្រុងប៉េកាំង*

## ១.១ គោលបំណង

បទដ្ឋានអប្បបរមាទាំងនេះមានគោលបំណងបង្កើនគុណភាពនៃការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីដែលជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ (សូមមើលនៅទំព័រមុន) ដែលផ្តល់ដោយអ្នកផ្តល់សេវាដំបូងបំផុត។ បទដ្ឋានអប្បបរមាទាំងនេះត្រូវបានរៀបចំឡើងផ្អែកទៅតាមគោលការណ៍ដែលកំណត់ថាបុគ្គលិកអ្នកស្ម័គ្រចិត្ត (រួមទាំងអ្នកស្ម័គ្រចិត្តនៅកម្រិតសហគមន៍ផង) និងអ្នកមានកាតព្វកិច្ចដែលផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រត្រូវមានជំនាញជាមូលដ្ឋានក្នុងការផ្តល់ប្រឹក្សា សូម្បីតែពួកគេផ្តល់សេវាផ្សេងៗដូចជាជំនួយច្បាប់ការបណ្តុះបណ្តាល ការធ្វើសមាហរណកម្ម ឬការថែទាំសុខភាពក៏ដោយ។

បទដ្ឋានអប្បបរមាទាំងនេះផ្តល់ការណែនាំអំពីរបៀបដែលបុគ្គលិក និងអ្នកស្ម័គ្រចិត្តរបស់អ្នកផ្តល់សេវាធ្វើការប្រាស្រ័យទាក់ទង និងទំនាក់ទំនងជាមួយអ្នកផ្តល់សេវារួមនឹងអ្នកដែលកំពុងបំពេញតួនាទីផ្តល់ប្រឹក្សា និងអ្នកដែលបំពេញតួនាទីផ្សេងទៀតផងដែរ។ ដូច្នេះបទដ្ឋានអប្បបរមានេះបង្ហាញពីសំណុំជំនាញ និងឥរិយាបថដែលចាំបាច់សម្រាប់ឆ្លើយតបឱ្យបានសមស្របដល់ជនរងគ្រោះ។

## ១.២ ក្របខ័ណ្ឌច្បាប់ស្តីពីអំពើហិង្សាលើស្ត្រីក្នុងប្រទេសកម្ពុជា[៣]

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងគួរឱ្យកត់សម្គាល់ជាច្រើន ដោយបានដាក់ចេញនូវគោលនយោបាយជាតិ និងក្របខ័ណ្ឌច្បាប់ ដើម្បីឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី។ ខាងក្រោមនេះ គឺជាព័ត៌មានសង្ខេបអំពីច្បាប់ និងគោលនយោបាយទាំងនេះ។

**អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW)៖** ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា CEDAW នេះក្នុងឆ្នាំ ១៩៩២ និងពិធីសារបន្ថែមរបស់អនុសញ្ញានេះ ក្នុងឆ្នាំ ២០១០។ ក្នុងនាមជាប្រទេសហត្ថលេខីនៃអនុសញ្ញា CEDAW នេះ និងស្របតាមទំនួលខុសត្រូវ ដែលត្រូវបានដាក់ចេញក្នុងផែនការសកម្មភាពទីក្រុងប៉េកាំង ប្រទេសកម្ពុជាបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអនុម័តច្បាប់ និងគោលនយោបាយនានាដែលអាចឆ្លើយតបចំពោះអំពើហិង្សាក្នុងគ្រួសារ។

**រដ្ឋធម្មនុញ្ញ (១៩៩៣)** ផ្តល់ឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូប នូវសិទ្ធិរស់រានមានជីវិត សេរីភាពផ្ទាល់ខ្លួន និងសន្តិសុខ (មាត្រា ៣២) និងធានាថានឹងពុំមានការរំលោភបំពានផ្លូវកាយដល់បុគ្គលណាម្នាក់ឡើយ (មាត្រា ៣៨)។

**ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (២០០៥)** ដាក់ចេញការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋានក្នុងការធ្វើអន្តរាគមន៍ក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារកើតឡើង និងតម្រូវឱ្យតុលាការចេញដីកាការពារ ដើម្បីការពារជនរងគ្រោះ មិនឱ្យទទួលរងអំពើហិង្សាបន្ថែមទៀត។

**ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (២០០៨)** គឺជាច្បាប់ប្រឆាំងការជួញដូរមនុស្ស ដើម្បីកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬផ្លូវភេទ ហើយ **មាត្រា ៣១** នៃច្បាប់នេះ ចាត់ទុកការគ្រប់គ្រងគ្រឹះស្ថានណាមួយ សម្រាប់គោលបំណងពេស្យាកម្មជាទង្វើខុសច្បាប់។

---

៣ ដកស្រង់ចេញពីផែនការសកម្មភាពស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី២០១៤-២០១៨

**ក្រមព្រហ្មទណ្ឌ**(**២០០៩**) ចាត់ទុកអំពើហិង្សាក្នុងគ្រួសារថាជាបទល្មើសដែលអាចផ្តន្ទាទោសជាប់ពន្ធនាគារទៅតាមកម្រិតនៃបទល្មើសដែលមានចែងក្នុងក្រមនេះដូចជា អំពើហិង្សាដោយចេតនាលើសហព័ទ្ធ ឬកុមារជាដើម។ ក្រមព្រហ្មទណ្ឌចែងថា នីតិភាពសម្រាប់ផ្តល់ការយល់ព្រមរួមភេទ គឺ ១៥ ឆ្នាំ។ ក្រមព្រហ្មទណ្ឌក៏មានបញ្ញត្តិផ្តន្ទាទោសជាប់ពន្ធនាគារ សម្រាប់ករណីរំលោភសេពសន្ថវៈផងដែរ។

**ក្រមរដ្ឋប្បវេណី** (**២០០៧**) ចែងថា សមាជិកគ្រួសារត្រូវគោរពសិទ្ធិ និងសេរីភាពគ្នាទៅវិញទៅមក និងត្រូវទប់ស្កាត់មិនឱ្យមានអំពើហិង្សាក្នុងគ្រួសារកើតមានឡើយ។

**ក្រោមមាត្រា** (**១៧២**) **នៃច្បាប់ស្តីពីការងាររបស់កម្ពុជា** (**១៩៩៧**) និង**ក្រមព្រហ្មទណ្ឌ** (**២០១០**) ការបៀតបៀនផ្លូវភេទ និងកិរិយាមារយាទមិនសមរម្យនៅកន្លែងធ្វើការត្រូវបានហាមឃាត់។

**គោលនយោបាយភូមិឃុំមានសុវត្ថិភាព** (**២០១០**) ដែលចេញដោយក្រសួងមហាផ្ទៃ ចាត់ទុកការរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារ និងការប្រឆាំងការជួញដូរមនុស្ស ថាជាអាទិភាពដែលក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្តត្រូវឆ្លើយតប។ គោលនយោបាយនេះជំរុញឱ្យមានការសហការគ្នារវាងអាជ្ញាធរមូលដ្ឋាន និងវិស័យទាំងអស់ដូចជា គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងប្រជាពលរដ្ឋ ដើម្បីកសាងកម្លាំងរួមសកម្មភាពរួម និងវិធានការរួម ដើម្បីអនុវត្តគោលនយោបាយនេះ។

## ១.៣ តើអ្នកណាដែលគួរអនុវត្តបទដ្ឋានអប្បបរមាទាំងនេះ?

បទដ្ឋានអប្បបរមាទាំងនេះមានគោលបំណងផ្តល់ការណែនាំដល់បុគ្គលិក អ្នកស្ម័គ្រចិត្ត និងអ្នកមានកាតព្វកិច្ចទាំងអស់ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងស្ត្រីដែលទទួលរងអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។ អ្នកផ្តល់សេវាត្រូវបានលើកទឹកចិត្តឱ្យយកបទដ្ឋានអប្បបរមាទាំងនេះទៅអនុវត្តក្នុងអង្គការ ស្ថាប័នរបស់ខ្លួនដើម្បីជានាគុណភាពសេវា និងការពារសិទ្ធិជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។ បទដ្ឋានអប្បបរមាទាំងនេះគួរប្រើប្រាស់ដោយអ្នកផ្តល់សេវា និងអ្នកមានភារកិច្ចដែលផ្តល់ការថែទាំសុខភាព ជម្រកសុវត្ថិភាព និងសេវាគាំទ្រ អន្តរាគមន៍ផ្លូវច្បាប់ និងការឆ្លើយតបជាការការពារ។

## ១.៤ ដែនកំណត់

បទដ្ឋានអប្បបរមាទាំងនេះ គឺជាសំណុំជំនាញជាមូលដ្ឋានសំខាន់ចាំបាច់សម្រាប់អ្នកផ្តល់

សេវាទាំងអស់ ដែលធ្វើការងារជាមួយជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ ប៉ុន្តែ បទដ្ឋានអប្បបរមាទាំងនេះមិនមែនសម្រាប់បញ្ជាក់ថាអ្នកណាម្នាក់ គឺជាអ្នកផ្តល់ប្រឹក្សាកម្រិតវិជ្ជាជីវៈនោះទេ ហើយការអនុវត្តបទដ្ឋានអប្បបរមាទាំងនេះ មិនអាចជំនួសឱ្យដំណើរការរយៈពេលវែងដើម្បីទទួលបានជំនាញផ្តល់ប្រឹក្សាកម្រិតវិជ្ជាជីវៈតាមរយៈការសិក្សាពីការផ្តល់ប្រឹក្សានៅតាមសាកលវិទ្យាល័យដែលបានទទួលការបញ្ជាក់គុណភាព និងមានផ្តល់ជាសញ្ញាបត្រនោះដែរ។

រាល់សេវាទាំងអស់ដែលផ្តល់ដល់ជនរងគ្រោះ ដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ គួរអនុវត្តតាមដំណើរការគ្រប់គ្រងករណីប្រកបដោយប្រសិទ្ធភាព។ ឯកសារនេះពុំបានកំណត់ពីបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងករណីនោះទេ។

លើសពីនេះ បទដ្ឋានអប្បបរមាទាំងនេះនឹងមិនឆ្លើយតបចំពោះតម្រូវការជាក់លាក់ក្នុងការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់កុមារដែលជាកូនជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ ដោយសារវាជាជំនាញឯកទេសមួយទៀត។

## បុរស និងអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ

បុរសក៏អាចទទួលរងអំពើហិង្សាពីដៃគូ និងការបំពានផ្លូវភេទផងដែរ។ ប៉ុន្តែជាទូទៅស្ត្រីទទួលរងអំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវកាយធ្ងន់ធ្ងរ និងឃាតកម្ម ... 

ខណៈពេលដែលបទដ្ឋានអប្បបរមាទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីផ្តោតលើអំពើហិង្សាលើស្ត្រី ដំបូន្មានជាច្រើនក៏ពាក់ព័ន្ធជាមួយនឹងអំពើហិង្សាលើបុរសផងដែរ។

# ២. គោលការណ៍ណែនាំ និងគុណតម្លៃ សម្រាប់ផ្តល់ការថែទាំដែលផ្តោតលើជនរងគ្រោះ

### អភិក្រម/វិធីសាស្រ្តសិទ្ធិមនុស្ស

អំពើហិង្សាលើស្ត្រី គឺជាការរំលោភបំពានសិទ្ធិមនុស្ស និងមិនអាចទទួលយកបានឡើយ ទោះជាក្នុងទម្រង់អ្វីក៏ដោយ។

### ធានាសុវត្ថិភាព

អាទិភាពទីមួយ គឺសុវត្ថិភាពរបស់ជនរងគ្រោះ។ រាល់សកម្មភាពទាំងអស់ត្រូវមានគោលបំណងស្តារ ឬរក្សាសុវត្ថិភាព និងមិនត្រូវធ្វើឱ្យជនរងគ្រោះប្រឈមនឹងហានិភ័យកាន់តែច្រើនជាងមុនឡើយ។

### ផ្តល់ភាពអង់អាចក្នុងការអនុវត្តជាក់ស្តែង

ការផ្តល់ព័ត៌មានអំពីជម្រើសនានា អាចជួយឱ្យជនរងគ្រោះធ្វើការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវសម្រាប់ខ្លួនឯង។ គេត្រូវស្តាប់ការយល់ឃើញ និងគំនិតរបស់ជនរងគ្រោះនិងផ្តល់ឱ្យពួកគេនូវការគោរព។ នេះជាអ្វីដែលគេហៅថាការប្រើប្រាស់អភិក្រម/វិធីសាស្រ្តផ្តល់ភាពអង់អាច ឬអភិក្រម/វិធីសាស្រ្តដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។ ខណៈពេលដែលព័ត៌មានអាចផ្តល់ភាពអង់អាចឱ្យជនរងគ្រោះធ្វើការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវ ជនរងគ្រោះមានសិទ្ធិធ្វើការសម្រេចចិត្តពីជំនួយដែលពួកគេចង់បាន និងអាចបដិសេធមិនទទួលយកសេវាណាមួយ។

### ឥរិយាបថមិនបន្ទោស និងមិនវិនិច្ឆ័យ

ជនរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាល អំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាផ្សេងទៀត មិនត្រូវទទួលរងការបន្ទោស ដោយអំពើហិង្សាដែលបានកើតឡើងឡើយ។ អំពើហិង្សាលើស្ត្រី គឺជាទង្វើខុសនឹងច្បាប់នៃប្រទេសកម្ពុជាហើយជនដែលប្រព្រឹត្តត្រូវតែទទួលខុសត្រូវ។

## ការរក្សាភាពជាឯកជន និងការរក្សាការសម្ងាត់

នៅគ្រប់ពេលវេលាទាំងអស់ត្រូវមានការគោរពភាពជាឯកជន និងរក្សាការសម្ងាត់ជូនជនរងគ្រោះ និងគ្រួសាររបស់ពួកគេ។ ការផ្តល់សេវា គួរធ្វើឡើងនៅកន្លែងស្ងប់ស្ងាត់ ដែលអាចរក្សាបាននូវភាពឯកជន។ នៅពេលដែលជនរងគ្រោះលើកឡើងពីអំពើហិង្សាប្រសិនបើមានអ្នកផ្សេងទៀតនៅជិតនោះ សូមឱ្យពួកគេចាកចេញ ឬទៅកន្លែងមួយផ្សេងទៀតដែលពុំមានអ្នកណាអាចស្តាប់ឮដើម្បីការពារភាពជាឯកជនរបស់ពួកគេ។

មិនគួរយកអត្តសញ្ញាណរបស់ជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ ទៅចែករំលែក ឬពិភាក្សាក្នុងកិច្ចប្រជុំ ឬជាមួយអ្នកផ្តល់សេវាណាផ្សេងទៀតខាងក្នុងឬខាងក្រៅមូលដ្ឋានសុខាភិបាលដោយពុំមានការអនុញ្ញាតពីជនរងគ្រោះឡើយ។ សម្រាប់ការពិគ្រោះយោបល់ ឬការផ្តល់ដំបូន្មានអំពីរបៀបគ្រប់គ្រងករណីពីអ្នកផ្តល់សេវាមួយទៀតសូមកុំប្រើឈ្មោះជនរងគ្រោះលើកលែងតែមានការអនុញ្ញាត។

## ការមិនរើសអើង

ជនរងគ្រោះទាំងអស់ត្រូវទទួលបានការប្រតិបត្តិដូចគ្នា និងអាចទទួលបានសេវាស្មើគ្នា។ មិនត្រូវមានការរើសអើង ឬការប្រតិបត្តិផ្សេងគ្នាលើជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រដោយសារតែជាតិពន្ធ សាសនា វណ្ណៈក្នុងសង្គម ពិការភាព អាយុ ទំនោរផ្លូវភេទ ឬកត្តាផ្សេងទៀតឡើយ។

# ៣. បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ

## បទដ្ឋានទី១ ៖ ការផ្តល់ប្រឹក្សាជាមូលដ្ឋាន-ការជំរុញឱ្យមានការចូលរួមពីស្ត្រីដែលជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ

**លទ្ធផល**

**ស្ត្រីដែលជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រទាំងអស់ទទួលបានការប្រតិបត្តិដោយការគោរពនៅពេលដែលពួកគេស្វែងរកការគាំទ្រ ឬ ការគាំទ្រពីអ្នកផ្តល់សេវា**

អ្នកផ្តល់សេវាដែលធ្វើអន្តរាគមន៍ ឬ ឆ្លើយតបដល់ស្ត្រីដែលជាជនរងគ្រោះដោយអំពើហិង្សាគួរឆ្លើយតបតាមបែបផែនមួយដែលជួយផ្តល់ភាពអង់អាចដល់ជនរងគ្រោះតាមរយៈការស្តាប់ ការបកស្រាយ និងការឆ្លើយតបក្នុងលក្ខណៈជាប្រព័ន្ធដើម្បីឱ្យជនរងគ្រោះមានភាពអង់អាចដើម្បីធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង។

១.១ នៅពេលជួបជនរងគ្រោះជាលើកទីមួយអ្នកផ្តល់សេវាត្រូវជំរុញឱ្យមានការចូលរួមពីជនរងគ្រោះ តាមរយៈប្រតិបត្តិជាមួយពួកគេដោយការគោរព និងសុជីវធម៌ដូចជា៖

- ណែនាំខ្លួនឯង ដល់ជនរងគ្រោះ
- នាំជនរងគ្រោះទៅកន្លែងស្ងាត់ដើម្បីនិយាយគ្នា
- ប្រើប្រាស់ជំនាញស្តាប់តាមបែបសកម្មក្នុងការបង្កើតនូវបរិយាកាសវិជ្ជមានដើម្បីដឹងពីតម្រូវការ និងការព្រួយបារម្ភរបស់នាង
  - និយាយដោយសុភាពរាបសារ និងដោយការគោរព ទៅកាន់ជនរងគ្រោះដោយសាកសួរពីតម្រូវការ និងការព្រួយបារម្ភរបស់នាង។ ឱ្យនាងនិយាយពីរឿងរបស់

នាងដោយមិនត្រូវនិយាយកាត់។ សួរសំណួរបើក និងទុកពេលឱ្យជនរងគ្រោះនិយាយ។

- ផ្ទះបញ្ចាំងសារជាថ្មីលើអ្វីដែលនាងបាននិយាយដើម្បីជានាឱ្យប្រាកដថា អ្នកពិតជាបានយល់មែន។
- ប្រើប្រាស់ភាសាកាយវិការដូចជាទំនាក់ទំនងតាមកែវភ្នែក ងក់ក្បាល និងទេរខ្លួនទៅមុខដើម្បីបង្ហាញថាអ្នកកំពុងយកចិត្តទុកដាក់។

### ១.២ អ្នកផ្តល់សេវាត្រូវស្វែងយល់ពីបញ្ហាចេញពីទស្សនវិស័យរបស់ជនរងគ្រោះ និងមិនត្រូវស្តីបន្ទោសជនរងគ្រោះចំពោះអំពើហិង្សាដែលបានកើតមានឡើងឡើយ។

កុំសួរជនរងគ្រោះថាតើពួកគេបានធ្វើអ្វីខ្លះ ដែលនាំអោយមានអំពើហឹង្សាកើតឡើង ឬហេតុអ្វីបានជាជននោះប្រព្រឹត្តអំពើហឹង្សា។ គេមិនត្រូវបន្ទោសជនរងគ្រោះ ចំពោះអំពើហឹង្សាដែលបានកើតឡើងនោះឡើយ។

***សម្គាល់*** ៖ *នេះគឺការឆ្លើយតបសំខាន់ជាងគេដែលអ្នកអាចផ្តល់ឱ្យបាន។ បើទោះបីជាអ្វីដែលអ្នកអាចធ្វើបាន គឺគ្រាន់តែស្តាប់ និងប្រតិបត្តិចំពោះជនរងគ្រោះដោយសារការគោរពយ៉ាងណាក៏ដោយក៏អ្នកបានជួយដល់ពួកគេរួចទៅហើយ។ សូមចាំថាអ្នកពុំមានការទទួលខុសត្រូវដោះស្រាយបញ្ហារបស់ជនរងគ្រោះឡើយ ហើយអ្នកគួរគោរពសិទ្ធិរបស់ជនរងគ្រោះក្នុងការធ្វើការសម្រេចចិត្តដោយខ្លួនឯងក៏ដូចជាភាពឯកជន និងការរក្សាការសម្ងាត់។*

## បទដ្ឋានទី២ ៖ ការផ្តល់ប្រឹក្សាជាមូលដ្ឋាន-ការរៀបចំផែនការសុវត្ថិភាពសម្រាប់ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ

**លទ្ធផល**

**មានការវាយតម្លៃ និងរៀបចំផែនការរក្សាសុវត្ថិភាពជាមួយនឹងស្ត្រីរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រដែលកំពុងស្វែងរកជំនួយ**

សុវត្ថិភាពរបស់ជនរងគ្រោះ និងកូនៗរបស់នាង គឺមានសារៈសំខាន់យ៉ាងខ្លាំង។ អ្នកផ្ដល់សេវាគួរវាយតម្លៃគ្រោះថ្នាក់ខាងផ្លូវកាយ និងផ្លូវចិត្ត ចំពោះនាង កូនៗរបស់នាង និងអ្នកផ្ដល់សេវា។

### ២.១ អ្នកផ្ដល់សេវាត្រូវជួយជនរងគ្រោះធ្វើការវាយតម្លៃសុវត្ថិភាពបន្ទាន់ និងក្នុងរយៈពេលវែង ដូចជា៖

- ធ្វើការវាយតម្លៃលើសុវត្ថិភាពផ្លូវកាយរបស់ជនរងគ្រោះ។ ប្រសិនបើពុំមានពិធីសារផ្សេងទៀតនោះទេ សំណួរមួយចំនួនដែលត្រូវសួររួមមាន៖
    - តើឥឡូវនេះជនប្រព្រឹត្តអំពើហិង្សា មានគំរាមកំហែងដែរ ឬទេ? (ប្រសិនបើដូច្នេះមែនគួរពិចារណាទូរស័ព្ទប្រាប់នគរបាល)
    - តើអំពើហិង្សានេះបានកើតឡើងលើសពីម្ដងក្នុងរយៈពេល ៦ខែ ចុងក្រោយដែរ ឬទេ?
    - តើជនប្រព្រឹត្តអំពើហិង្សាបានប្រើអាវុធ ឬបានប្រើអាវុធគំរាមកំហែងអ្នកដែរ ឬទេ?
    - តើអ្នកធ្លាប់ទទួលការវាយដំនៅពេលដែលអ្នកមានផ្ទៃពោះដែរ ឬទេ?
    - តើគាត់ប្រច័ណ្ឌអ្នកខ្លាំងដែរ ឬទេ?
- ការរៀបចំផែនការសុវត្ថិភាពគួរមានស្តង់ដាមួយរបស់អ្នកផ្ដល់សេវាទាំងអស់ នៅពេលដែលពួកគេទំនាក់ទំនងជាមួយជនរងគ្រោះជាលើកដំបូង។ ប្រសិនបើស្ត្រីឆ្លើយថា "ចាស" ចំពោះសំណួរណាមួយក្នុងចំណោមសំណួរខាងលើ គាត់ប្រហែលជាពុំមានសុវត្ថិភាពក្នុងការវិលត្រលប់ទៅផ្ទះវិញឡើយ ដូច្នេះគួរបញ្ជូននាងទៅកន្លែងដែលមានសុវត្ថិភាពដូចជា ផ្ទះមិត្តភក្តិ ឬសមាជិកគ្រួសារ ឬជម្រកសុវត្ថិភាព ប្រសិនបើនាងយល់ព្រម។

### ២.២ អ្នកផ្ដល់សេវាត្រូវបង្កើតនូវបរិយាកាសដែលជនរងគ្រោះមានអារម្មណ៍សុវត្ថិភាពផ្លូវចិត្ត និងផ្លូវកាយដូចជា៖

- ធ្វើការប្រាស្រ័យទាក់ទងប្រកបដោយការគោរពដើម្បីធានាថា ជនរងគ្រោះពុំមានអារម្មណ៍ថាទទួលរងការគំរាមកំហែង ដោយសារសំណួររបស់អ្នកផ្ដល់សេវានោះទេ (សូមមើលស្តង់ដាទី១)

- ធានាសុវត្ថិភាពជារួមដោយរក្សាការសម្ងាត់ចំពោះព័ត៌មានរបស់ជនរងគ្រោះ (ដូចជាទីតាំងជាដើម)។ នេះ គឺជាអ្វីដែលមានសារៈសំខាន់ជាពិសេសដើម្បីការពារជនរងគ្រោះដោយមិនធ្វើឱ្យនាងប្រឈមនឹងហានិភ័យដោយសារការចែករំលែកព័ត៌មានដែលនាងរាយការណ៍ប្រាប់អ្នក និងការពារពីបញ្ហាផ្សេងទៀតដែលអាចកើតឡើងដោយសារការបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់ជនរងគ្រោះ (សូមមើលបទដ្ឋានទី៥)

## បទដ្ឋានទី៣ ៖ ការផ្តល់ប្រឹក្សាជាមូលដ្ឋាន-ការផ្តល់ព័ត៌មានអំពីសេវា និងការឆ្លើយតបដល់ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សារួមទាំងជនដែលងាយរងគ្រោះផង[៤]

### លទ្ធផល

**ស្ត្រីដែលជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័ររួមទាំងស្ត្រីក្នុងក្រុមងាយរងគ្រោះផងទទួលបានព័ត៌មានអំពីសេវា និងអាចទទួលបានសេវា និងការឆ្លើយតបដោយពុំមានការរើសអើង**

ជនរងគ្រោះច្រើនស្ថិតក្នុងសភាពតានតឹងខ្លាំងនៅពេលស្វែងរកជំនួយ។ តួនាទីរបស់អ្នកផ្តល់សេវាគឺត្រូវផ្តល់ព័ត៌មានជាមូលដ្ឋានអំពីសេវាឆ្លើយតបដែលមាន និងសេវាគាំទ្រនានាដើម្បីឱ្យជនរងគ្រោះអាចធ្វើការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវអំពីជម្រើសនានា។ អ្នកផ្តល់សេវាគួរផ្តោតការយកចិត្តទុកដាក់ជាបន្ទាន់លើតម្រូវការជាមូលដ្ឋានក្រោយសុវត្ថិភាព (ដូចជាការថែទាំសុខភាព

---

៤ នេះរួមមានស្ត្រី និងក្មេងស្រីពិការ ចាស់ជរា ស្ត្រីស្រលាញ់ស្ត្រីដូចគ្នា អ្នកប្តូរយេនឌ័រស្ត្រី និងក្មេងស្រីមកពីក្រុមជនជាតិដើមភាគតិច និងមកពីក្រុមជនជាតិភាគតិច និងក្រុមកាន់សាសនាភាគតិច ស្ត្រីដែលទទួលរងអំពើហិង្សាផ្លូវភេទនិង/ឬទទួលរងការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម ស្ត្រី និងក្មេងស្រីរស់នៅជាមួយមេរោគអេដស៍ ស្ត្រីជាពលករចំណាកស្រុក ស្ត្រី និងក្មេងស្រីរស់នៅតំបន់ដាច់ស្រយាល ស្ត្រីរស់នៅក្នុងពន្ធនាគារ និងស្ត្រីដែលប្រឡូកក្នុងរបរពេស្យាចារនិង/ឬធ្វើការងារក្មេងវិស័យកម្សាន្តសប្បាយ (ក្រសួងកិច្ចការនារីការវាយតម្លៃយេនឌ័រកម្ពុជា ៖ ក្រុមស្ត្រី និងក្មេងស្រីងាយរងគ្រោះ ២០១៤)

ចំណីអាហារ ជម្រកសុវត្ថិភាព។ល។)។ នេះជាពេលសំខាន់ដែលត្រូវរំឭកប្រាប់ស្ត្រីពីសិទ្ធិរបស់នាងដើម្បីរស់ដោយគ្មានអំពើហិង្សា និងការពារនាងព្រមទាំងកូនៗរបស់នាងខណៈពេលដែលនាងពិនិត្យលើជម្រើសនានា។ ប៉ុន្តែអ្នកផ្តល់សេវាត្រូវទទួលយកការសម្រេចចិត្តរបស់នាងទោះជាការសម្រេចចិត្តបែបណាក៏ដោយ។

៣.១ អ្នកផ្តល់សេវាត្រូវផ្តល់ព័ត៌មានអំពីសេវា និងការឆ្លើយតប និងរបៀបទទួលបានសេវានិងការឆ្លើយតប ដល់ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សាដោយពុំមានការរើសអើងរួមទាំងស្ត្រីដែលប្រឈមខ្លាំងនឹងភាពងាយរងគ្រោះដូចដែលកំណត់ក្នុងក្រុមងាយរងគ្រោះខាងលើ។

៣.២ ព័ត៌មានដែលផ្តល់ឱ្យស្ត្រីរងគ្រោះត្រូវជាព័ត៌មានសុក្រឹត គ្រប់ជ្រុងជ្រោយ និងផ្តល់ក្នុងទម្រង់ដែលជនរងគ្រោះអាចយល់បាន។ នេះមានន័យថា អ្នកផ្តល់សេវាត្រូវផ្តោតការយកចិត្តទុកដាក់លើ៖

- ភាសា ដែលជនរងគ្រោះនិយាយ
- ថាតើជនរងគ្រោះចេះអាន និងសរសេរ ឬអត់និង
- ថាតើជនរងគ្រោះមានពិការភាពខាងសតិបញ្ញា ឬកាយសម្បទាដែលរារាំងពួកគេមិនឱ្យស្តាប់ឮ អាន ឬយល់ព័ត៌មានដែរឬទេ

៣.៣ ប្រសិនបើអ្នកផ្តល់សេវា ឬអ្នកមានកាតព្វកិច្ចមិនដឹងពីសេវា និងការឆ្លើយតបដែលមាន ពួកគេត្រូវបញ្ជូនជនរងគ្រោះជាបន្ទាន់ទៅកាន់មន្ទីរកិច្ចការនារី អង្គការមិនមែនរដ្ឋាភិបាល ឬអ្នកផ្តល់សេវាផ្សេងទៀតដែលអាចផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីជម្រើសនានាសម្រាប់ជនរងគ្រោះ។

៣.៤ ជម្រើសសេវា និងការឆ្លើយតបនានាអាចមានជាអាទិ៍ ការថែទាំសុខភាពជាបន្ទាន់ នគរបាលសេវាសង្គម ជម្រកសុវត្ថិភាព ការផ្តល់ប្រឹក្សាចិត្តសង្គម និងក្រុមគាំទ្រ ឬសេវាផ្សេងទៀតទៅតាមតម្រូវការរបស់ជនរងគ្រោះ។ ជនរងគ្រោះគួរទទួលបានព័ត៌មានពីគ្រប់ជម្រើសទាំងអស់រួមនឹងអំពីសារៈសំខាន់នៃប្រភេទនៃការថែទាំផង។ ខណៈពេលដែលជនរងគ្រោះជានិច្ចកាលគួរអាចបដិសេធមិនទទួលសេវាណាមួយ នាងអាចស្ថិតក្នុងសភាពតានតឹងផ្លូវចិត្តខ្លាំងហើយគួរទទួលបានព័ត៌មានច្បាស់លាស់ពីជម្រើសផ្សេងៗដើម្បីឱ្យនាងអាចយល់ពីសារៈសំខាន់នៃជម្រើសទាំងនោះ។ ឧទាហរណ៍ ជនរងគ្រោះដោយសារការរំលោភសេពសន្ថវៈគួរទទួលបានព័ត៌មានច្បាស់លាស់ពីសារៈសំខាន់នៃការថែទាំ

សុខភាពសម្រាប់ការបង្ការមេរោគអេដស៍ ឬជំងឺកាមរោគ ដើម្បីជួយឱ្យនាងធ្វើការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវ។

៣.៥ អ្នកផ្តល់សេវាត្រូវផ្តល់ព័ត៌មានស្របតាមស្ថានភាពជាក់ស្តែង/ប្រាកដនិយមដល់ជនរងគ្រោះ និងចៀសវាងដាច់ខាតមិនត្រូវឱ្យជនរងគ្រោះមានការរំពឹងទុកដែលពុំមានភាពប្រាកដនិយមឡើយ។

## បទដ្ឋានទី៤ ៖ ការផ្តល់ប្រឹក្សាជាមូលដ្ឋាន-ការផ្តល់ជម្រើសការធ្វើសេចក្តីសម្រេចចិត្ត និងការកំណត់ដោយខ្លួនឯង

**លទ្ធផល**

**ជនរងគ្រោះសម្រេចចិត្តដោយខ្លួនឯងអំពីសេវា ឬ ការការពារដែលពួកគេត្រូវទទួលយក**

ក្រោយពីបានទទួលព័ត៌មានរួចជនរងគ្រោះត្រូវធ្វើការសម្រេចចិត្តដោយខ្លួនឯងអំពីអ្វីដែលពួកគេត្រូវធ្វើ។ ក្រោយពីបានទទួលព័ត៌មានគ្រប់គ្រាន់ និងធ្វើការពិភាក្សាពីផលវិបាកនានារួចជំហានដំបូងដើម្បីផ្តល់ភាពអង់អាចដល់ជនរងគ្រោះ គឺត្រូវឱ្យនាងធ្វើការសម្រេចចិត្តនិងរៀបចំផែនការដោយខ្លួនឯង។

៤.១ អ្នកផ្តល់សេវាត្រូវទទួលស្គាល់ថាមនុស្សដែលធ្លាប់ទទួលរងអំពើហិង្សាទំនងជាត្រូវបានជនប្រព្រឹត្តអំពើហិង្សាដកហូតអំណាច (ប្រឆាំងនឹងឆន្ទៈរបស់ពួកគេ) ទាំងខាងផ្លូវកាយទាំងផ្លូវចិត្តហើយការផ្តល់ភាពអង់អាច (ឱ្យពួកគេធ្វើការសម្រេចចិត្តដោយខ្លួនឯងតាមរយៈការផ្តល់ព័ត៌មានគ្រប់គ្រាន់) គឺជាផ្នែកមួយដ៏សំខាន់សម្រាប់ការជួរសើ្បយរបស់ជនរងគ្រោះ។

៤.២ អ្នកផ្តល់សេវាមានកាតព្វកិច្ចផ្តល់ព័ត៌មានពេញលេញអំពីជម្រើសសេវា និងការឆ្លើយតបនានា (សូមមើលបទដ្ឋានទី៣) ជាពិសេសសេវាដើម្បីបំពេញទៅតាមតម្រូវការបន្ទាន់ដូចជាសុវត្ថិភាពសុខភាព និងការគាំទ្រចិត្តសង្គម ជាដើម។

៤.៣ អ្នកផ្តល់សេវាត្រូវទទួលស្គាល់ថា ជនរងគ្រោះទាំងអស់មានសិទ្ធិធ្វើការសម្រេចចិត្តពីសេវា និងការឆ្លើយតបដែលពួកគេចង់បាន និងមិនចង់បាន អ្វីដែលពួកគេត្រូវការ និងមិនត្រូវការ



និងអ្វីដែលពួកគេទទួលយកបាន និងមិនអាចទទួលយកបាន។ ប៉ុន្តែអ្នកផ្តល់សេវាមានកាតព្វកិច្ចជួយឱ្យស្ត្រីយល់ពីផលវិបាកនៃជម្រើសរបស់ខ្លួន ដើម្បីឱ្យពួកគេមានព័ត៌មានពេញលេញ។

៤.៤ អ្នកផ្តល់សេវាគួរធ្វើការបញ្ជូនជនរងគ្រោះ ទៅអ្នកផ្តល់សេវាផ្សេងទៀត ឬសេវាឆ្លើយតបទៅតាមការព្រមព្រៀងរបស់ជនរងគ្រោះ។

## បទដ្ឋានទី៥ ៖ ការផ្តល់ប្រឹក្សាជាមូលដ្ឋាន-ភាពជាឯកជន និងការរក្សាការសម្ងាត់

**លទ្ធផល**

**ត្រូវមានការគោរពភាពជាឯកជនរបស់ស្ត្រីដែលជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រហើយត្រូវមានការរក្សាការសម្ងាត់ដល់ព័ត៌មានរបស់ពួកគេ**

ការភ័យខ្លាចថារឿងរ៉ាវរបស់ខ្លួននឹងត្រូវបានគេយកទៅប្រាប់អ្នកដទៃ គឺជាឧបសគ្គមួយចំពោះជនរងគ្រោះដែលស្វែងរកជំនួយ។ ការរក្សាភាពជាឯកជន និងការរក្សាការសម្ងាត់មានសារៈសំខាន់ដើម្បីឱ្យជនរងគ្រោះដឹងថាពួកគេអាចចែករំលែករឿងរ៉ាវរបស់ខ្លួន បានដោយរឿងរ៉ាវទាំងនេះនឹងមិនត្រូវបានយកទៅចែករំលែកជាមួយអ្នកដទៃដោយពុំមានការអនុញ្ញាតពីពួកគេឡើយ។ បទដ្ឋាននេះ គឺជាអ្វីដែលចាំបាច់ត្រូវអនុវត្តតាមដើម្បីលើកទឹកចិត្តឱ្យជនរងគ្រោះឱ្យបានច្រើននាក់បន្ថែមទៀតចេញមករកជំនួយ។

៥.១ ពុំមានព័ត៌មានណាអំពីជនរងគ្រោះ (ដូចជាឈ្មោះស្ថានភាព។ល។) ត្រូវបានគេចែកចាយ ដោយពុំមានការអនុញ្ញាតពីពួកគេឡើយ។ ករណីលើកលែងតែមួយគត់ គឺក្នុងស្ថានភាពអាចមានគ្រោះថ្នាក់ដែលចាំបាច់ត្រូវតែហៅអាជ្ញាធរមកដើម្បីការពារជនរងគ្រោះ និង/ឬកូនៗរបស់នាងពីគ្រោះថ្នាក់ដែលអាចកើតឡើងក្នុងពេលខ្លីខាងមុខ។

៥.២ មិនត្រូវលើកឈ្មោះ និងព័ត៌មានលំអិតឯកជនមកបង្ហាញក្នុងការសន្ទនាជាមួយនឹងមនុស្សផ្សេងទៀតឡើយរួមទាំងសហការីដែលមិនធ្វើការងារផ្ទាល់ជាមួយនឹងជនរងគ្រោះផង។ ជាពិសេសមិនត្រូវមានការចែករំលែកព័ត៌មាន តាមទីសាធារណៈ ឬតាមទូរស័ព្ទឡើយ។

៥.៣ ត្រូវមានការរក្សាទុកឯកសារអំពីជនរងគ្រោះឱ្យមានសុវត្ថិភាព និងជាប់លាប់ដើម្បីធានាថាឯកសារទាំងនេះនៅតែត្រូវបានរក្សាជាការសម្ងាត់។ នេះមានន័យថាឯកសារទាំងនេះត្រូវបានរក្សាទុកនៅកន្លែងមួយដែលមានតែអ្នកដែលធ្វើការងារជាមួយជនរងគ្រោះប៉ុណ្ណោះ

ដែលអាចចូលមើលបាន ឬអ្នកដទៃអាចចូលមើលបាននៅពេលដែលមានការស្នើសុំតាមច្បាប់ពីតុលាការ។

៥.៤ ប្រសិនបើចាំបាច់ត្រូវចែករំលែកព័ត៌មានសម្រាប់ការពិគ្រោះយោបល់អំពីករណីនេះអ្នកផ្តល់សេវាគួរលើកឡើងពីជនរងគ្រោះតាមបែបផែនមួយដែលការពារពួកគេមិនឱ្យគេដឹងពីអត្តសញ្ញាណឱ្យបានច្រើនតាមដែលអាចធ្វើបាន។ នេះមានន័យថា អ្នកផ្តល់សេវាគួរចៀសវាងលើកឡើងពីឈ្មោះសាច់ញាតិ អាសយដ្ឋាន ឬព័ត៌មានអត្តសញ្ញាណផ្សេងទៀត។

៥.៥ រាល់ចំណុចទាំងអស់ដែលលើកឡើងខាងលើក៏ត្រូវអនុវត្តចំពោះការឆ្លងឆ្លើយតាមអ៊ីម៉ែលផងដែរ។

## បទដ្ឋានទី៦ ៖ ការអនុវត្តល្អរបស់អ្នកផ្តល់សេវា-ការស្គាល់ខ្លួនឯងរបស់អ្នកផ្តល់សេវា

**លទ្ធផល**

**អ្នកផ្តល់សេវាគួរផ្តល់សេវាក្នុងដែនកំណត់នៃជំនាញ និងចំណេះដឹងរបស់ខ្លួនដោយពុំមានការវិនិច្ឆ័យ និងមិនលំអៀង**

៦.១ បុគ្គលិក អ្នកស្ម័គ្រចិត្ត និងអ្នកមានកាតព្វកិច្ចផ្តល់សេវាត្រូវបំពេញភារកិច្ចរបស់ខ្លួនផ្អែកទៅតាមគោលការណ៍ណែនាំ និងគុណតម្លៃក្នុងបទដ្ឋានអប្បបរមាទាំងនេះ។ អ្នកផ្តល់សេវាមិនត្រូវវិនិច្ឆ័យជនរងគ្រោះទៅតាមគុណតម្លៃ/ជំនឿផ្ទាល់ខ្លួនរបស់ខ្លួន ឬគុណតម្លៃ/ជំនឿរបស់អង្គការស្ថាប័នរបស់ខ្លួនឡើយ ហើយត្រូវស្តាប់ជនរងគ្រោះដោយមិនលំអៀង និងផ្តល់ឱ្យជនរងគ្រោះនូវការគាំទ្រដែលពួកគេត្រូវការ។

៦.២ អ្នកផ្តល់សេវាទទួលស្គាល់ថាអំពើហិង្សាលើស្ត្រីតែងតែជាទង្វើមិនត្រឹមត្រូវ ហើយជនរងគ្រោះមិនទទួលខុសត្រូវលើអំពើហិង្សា ការរំលោភបំពាន ឬការកេងប្រវ័ញ្ចដែលពួកគេទទួលរងនោះឡើយ។

៦.៣ អ្នកផ្តល់សេវាត្រូវជានា ចំពោះស្ត្រីដែលជាជនរងគ្រោះ ដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រថាគ្រោះថ្នាក់/ការរំលោភបំពាន/ការជួញដូរ ឬការកេងប្រវ័ញ្ចដែលពួកគេជួបប្រទះកន្លងមកមិនមែនជាកំហុសរបស់ពួកគេហើយត្រូវបញ្ជាក់ប្រាប់ពួកគេថាពួកគេមិនគួរមានអារម្មណ៍ថាខ្លួនជាអ្នកខុសឡើយ។ អ្នកផ្តល់សេវាចាំបាច់ត្រូវដឹងថាស្ត្រីដែលរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាលជារឿយៗព្យាយាមរកហេតុផលគាំទ្រ

ដល់ជនប្រព្រឹត្តហិង្សាទៅវិញហើយថែមទាំងមានអារម្មណ៍ថាខ្លួនខុស និងបន្ទោសខ្លួនឯងទៅវិញចំពោះការទទួលរងការឈឺចាប់ដោយអំពើហិង្សាបែបនេះ។

## បទដ្ឋានទី៧ ៖ ការអនុវត្តល្អរបស់អ្នកផ្តល់សេវា-ក្រមសីលធម៌ក្នុងការទំនាក់ទំនងរវាងអ្នកផ្តល់សេវា និងជនរងគ្រោះ

**លទ្ធផល**

**ជនរងគ្រោះទទួលបានកិច្ចការពារពីការកេងប្រវ័ញ្ចដោយចេតនា ឬ ដោយអចេតនាពីអ្នកផ្តល់សេវា**

អ្នកផ្តល់សេវាត្រូវរក្សាព្រំដែនឱ្យបានច្បាស់លាស់ជាមួយជនរងគ្រោះតាមលទ្ធភាពដែលអាចធ្វើបាន។

- អ្នកមិនមែនជាអ្នកដែលត្រូវទទួលខុសត្រូវដោះស្រាយបញ្ហារបស់ពួកគេឡើយប៉ុន្តែអ្នកត្រូវជួយពួកគេឱ្យយល់ពីជម្រើសនានា និងបង្កើនសុវត្ថិភាពរបស់ជនរងគ្រោះ និងកូនៗរបស់ពួកគេ។
- អ្នកផ្តល់សេវាជាបុរសគួរដឹងថាជនរងគ្រោះអាចមានការលំបាកក្នុងការនិយាយជាមួយនឹងមនុស្សប្រុស និងត្រូវផ្តល់អ្នកប្រឹក្សាជាស្ត្រីវិញប្រសិនបើមាន។

៧.២ អ្នកផ្តល់សេវាទទួលស្គាល់ថាការទទួលខុសត្រូវវិជ្ជាជីវៈរបស់ពួកគេចំពោះជនរងគ្រោះណាម្នាក់ គឺសំខាន់ជាងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ។ ទោះជាក្នុងកាលៈទេសៈណាក៏ដោយពួកគេមិនត្រូវកេងប្រវ័ញ្ចជនរងគ្រោះជាដាច់ខាតដូចជាការកេងប្រវ័ញ្ចផ្លូវភេទ ជាដើម។

៧.៣ អ្នកផ្តល់សេវាក៏ត្រូវចៀសវាងទំនាស់ផលប្រយោជន៍ផងដែរ។

- ទំនាស់ផលប្រយោជន៍រួមមានការធ្វើអន្តរាគមន៍ នៅពេលដែលអ្នកមានទំនាក់ទំនងជាមួយនឹងជនរងគ្រោះ ឬជនប្រព្រឹត្តអំពើហិង្សាដូចជាសាច់ញាតិមិត្តភក្តិជិតស្និទ្ធ ឬទំនាក់ទំនងជិតស្និទ្ធផ្សេងទៀត។
- ប្រសិនបើអ្នកផ្តល់សេវាសង្ស័យឬមានភស្តុតាងបង្ហាញថា អ្នកផ្តល់សេវាណាមួយកំពុងទាញប្រយោជន៍ឬរំលោភបំពានលើជនរងគ្រោះជាស្ត្រីនិង/ឬកូនៗរបស់ពួកគេ

ពួកគេត្រូវរាយការណ៍ពីស្ថានភាពនេះទៅកាន់ថ្នាក់លើរបស់ខ្លួន ហើយក្នុងពេលជាមួយគ្នាធានាថាជនរងគ្រោះនឹងមិនប្រឈមនឹងហានិភ័យខ្ពស់ជាងមុន ឬទទួលរងផលវិបាកអ្វីផ្សេងទៀតឡើយ។

## បទដ្ឋានទី៨ ៖ ការអនុវត្តល្អរបស់អ្នកផ្តល់សេវា-ការបង្កើតបណ្តាញ និងការបញ្ជូនរវាងអ្នកផ្តល់សេវា[5]

### លទ្ធផល

**អ្នកផ្តល់សេវាសហការគ្នាយ៉ាងមានប្រសិទ្ធភាពដើម្បីធានាយ៉ាងណាឱ្យជនរងគ្រោះអាចទទួលបានសេវាទាំងអស់ដែលពួកគេត្រូវការ**

៨.១ អ្នកផ្តល់សេវាទទួលស្គាល់ថាជនរងគ្រោះមានតម្រូវការច្រើនយ៉ាង ដែលមានលក្ខណៈស្មុគស្មាញហើយជារឿយៗទាមទារឱ្យមានការផ្តល់ការគាំទ្រឯកទេសមានលក្ខណៈទូលំទូលាយ និងគ្រប់ជ្រុងជ្រោយពីអ្នកផ្តល់សេវាជាច្រើនដែលជាស្ថាប័នរដ្ឋាភិបាលផង និងមិនមែនរដ្ឋាភិបាលផង។

៨.២ អ្នកផ្តល់សេវាត្រូវបន្តព្យាយាមរៀនសូត្រពីសេវាផ្សេងទៀតដែលមាន ក្នុងតំបន់របស់ពួកគេ បង្កើន និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ ជាមួយនឹងអ្នកផ្តល់សេវាជាស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះ។ ល្អបំផុតការរៀនសូត្រពីគ្នានេះគួរធ្វើឡើងក្នុងកិច្ចប្រជុំជាប្រចាំ ការចងក្រងបណ្តាញការផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់គ្នាទៅវិញទៅមកអំពីសេវាថ្មីៗ និងការតាមដានបន្តលើករណីនានា។

៨.៣ អ្នកផ្តល់សេវាគួរបញ្ជូនជនរងគ្រោះទៅរកសេវាផ្សេងទៀតដោយផ្អែកទៅលើតម្រូវការរបស់ពួកគាត់

---

5 ព័ត៌មានបន្ថែមអាចរកបានក្នុងគោលការណ៍ណែនាំអំពីការបញ្ជូន សម្រាប់ស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។

## បទដ្ឋានទី៩ ៖ ការអនុវត្តល្អរបស់អ្នកផ្តល់សេវា-ការថែទាំខ្លួនឯងរបស់អ្នកផ្តល់សេវា

**លទ្ធផល**

**អ្នកផ្តល់សេវាអាចថែទាំសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ខ្លួន និងបន្តផ្តល់ការគាំទ្រដល់ជនរងគ្រោះប្រកបដោយប្រសិទ្ធភាព**

៩.១ អ្នកផ្តល់សេវាគួរចាត់វិធានការដើម្បីបង្ការទប់ស្កាត់ ឬឆ្លើយតបចំពោះភាពតានតឹងដែលពួកគេជួបប្រទះនៅពេលធ្វើការងារជាមួយជនរងគ្រោះដូចជាតាមរយៈ ៖

- ការប្រើប្រាស់ការចុះអភិបាល/ផ្តល់ការណែនាំដើម្បីពិភាក្សាពីបទពិសោធន៍របស់ពួកគេក្នុងការធ្វើការងារជាមួយជនរងគ្រោះ
- ការស្នើសុំការគាំទ្រពីមិត្តភក្តិ ឬប្រធានក្រុម
- ការរក្សាគម្លាតវិជ្ជាជីវៈពីស្ថានភាពរបស់ជនរងគ្រោះនិង
- ការស្វែងរកការផ្តល់ប្រឹក្សាសម្រាប់ខ្លួនឯង

## បទដ្ឋានទី១០ ៖ ការអនុវត្តល្អរបស់អ្នកផ្តល់សេវា-ការចុះអភិបាលណែនាំ និងការគាំទ្រដោយអ្នកផ្តល់ប្រឹក្សាជំនាញ

**លទ្ធផល**

**ការងាររបស់អ្នកផ្តល់សេវាត្រូវមានការគាំទ្រ និងការតម្រង់ទិសពីអ្នកផ្តល់ប្រឹក្សាជំនាញ**

១០.១ ដើម្បីធានាឱ្យមានការគ្រប់គ្រងករណីទៅតាមលក្ខណៈបច្ចេកទេស និងវិជ្ជាជីវៈអ្នកផ្តល់សេវាត្រូវស្វែងរកការចុះអភិបាល/ការណែនាំជាប្រចាំពីអ្នកផ្តល់ប្រឹក្សាដែលមានជំនាញជាងខ្លួន(រៀងរាល់២ ទៅ ៣ខែម្តង)។

១០.២ ដើម្បីរក្សាគម្លាតវិជ្ជាជីវៈពីជនរងគ្រោះ អ្នកផ្តល់សេវាមិនគួរធ្វើការងារក្នុងករណីណាមួយតែឯងនោះទេ។

១០.៣ អ្នកដែលចុះអភិបាល/ផ្តល់ការណែនាំ គឺជាអ្នកផ្តល់ប្រឹក្សាជំនាញដែលមានចំណេះដឹង និងសមត្ថភាពដែលទទួលបានពីការបណ្តុះបណ្តាលការអប់រំ និងបទពិសោធន៍ការងារដែលមានការត្រួតពិនិត្យត្រឹមត្រូវ។

## បទដ្ឋានទី១១ ៖ ការអនុវត្តល្អរបស់អ្នកផ្ដល់សេវា-ការបណ្ដុះបណ្ដាលអ្នកផ្ដល់សេវាឱ្យយល់ដឹងពីអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ និងជំនាញផ្ដល់សេវាជាមូលដ្ឋាន

**លទ្ធផល**

**អ្នកផ្ដល់សេវាទទួលបានការបណ្ដុះបណ្ដាលគ្រប់គ្រាន់អំពីការផ្ដល់ប្រឹក្សាជាមូលដ្ឋាន និងមានការយល់ដឹងពីអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ**

១១.១ អ្នកផ្ដល់សេវាគួរទទួលបានការបណ្ដុះបណ្ដាលគ្រប់គ្រាន់ ដើម្បីអាចអនុវត្តបទដ្ឋានទាំងនេះដូចជា ៖

- ទិដ្ឋភាពទូទៅអំពីបទដ្ឋានអប្បបរមានេះ
- លក្ខណៈ និងផលវិបាកនៃអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ
  - ប្រភេទអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រលក្ខណៈនៃអំពើហិង្សាមកលើស្ត្រីក្នុងផ្ទះ សហគមន៍ និងកន្លែងធ្វើការ (វដ្តនៃអំពើហិង្សាលក្ខណៈនៃការរំលោភសេពសន្ថវៈការបៀតបៀនផ្លូវភេទ។ល។)
  - ផលវិបាកនៃអំពើហិង្សាលើកុមារ គ្រួសារ និងសហគមន៍ដូចជាសុខភាពចិត្តសង្គម និងសេដ្ឋកិច្ចជាដើម
- ជំនាញស្ដាប់ដោយយកចិត្តទុកដាក់
- ការរៀបចំផែនការសុវត្ថិភាពសម្រាប់ជនរងគ្រោះ
- ក្របខ័ណ្ឌច្បាប់ក្នុងប្រទេសកម្ពុជា
- ទិដ្ឋភាពទូទៅអំពីសេវា និងប្រភពឆ្លើយតបសម្រាប់ការបញ្ជូន

១១.២ អ្នកផ្ដល់សេវាគួរធ្វើការរំឭកឡើងវិញ និងបង្កើនចំណេះដឹង និងជំនាញរបស់ខ្លួនដើម្បីយល់ដឹងឱ្យបានកាន់តែប្រសើរពីរបៀបធ្វើការងារជាមួយនឹងស្ត្រីដែលជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។

**ក្រសួងកិច្ចការនារី**
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣
សង្កាត់ស្ទឹងមានជ័យ
ខណ្ឌមានជ័យ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

**ក្រសួងសុខាភិបាល**
ដីឡូត៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩)
សង្កាត់ បឹងកក់២ ខណ្ឌទួលគោក
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា